## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ៣៦៧/២៣ ក.ប/ប្រ.ក.ម.ហ

# ប្រកាស
## ស្តីពី
## ភាគព្វកិច្ចក្នុងការប្រើប្រាស់ហត្ថពលកម្មបរទេស

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នសរកម/០៣៩៧/០០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងប្រកាសអន្តរក្រសួងលេខ ៣៣៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងប្រកាសអន្តរក្រសួងលេខ ៤៩៨ សហវ.ប្រក.អទច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផាកពិន័យចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងប្រកាសលេខ ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីបណ្ណការងារ និងសៀវភៅការងារជនបរទេស
- យោងប្រកាសលេខ ១៩៦ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេស
- យោងប្រកាសលេខ ៣៥២ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

**ប្រការ១ ._**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ដែលមកប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានប្រើប្រាស់ហត្ថពលកម្មបរទេស ត្រូវមានកាតព្វកិច្ចធ្វើបណ្ណការងារ និងសៀវភៅការងារជនបរទេសឱ្យបានត្រឹមត្រូវ និងបំពេញលក្ខខណ្ឌផ្សេងៗទៀតតាមច្បាប់កំណត់។

**ប្រការ២ ._**

ការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

ក. កាតព្វកិច្ចរបស់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដែលមានប្រើប្រាស់ហត្ថពលកម្មបរទេស៖

- ត្រូវមានសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន
- ត្រូវមានការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេសប្រចាំឆ្នាំ
- ត្រូវបង្ហាញភស្តុតាងស្របច្បាប់អំពីការអនុញ្ញាតប្រកបអាជីវកម្មរបស់សហគ្រាស គ្រឹះស្ថានដល់កម្មករនិយោជិតជាជនបរទេស
- ត្រូវមានកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរជាមួយកម្មករនិយោជិតជាជនបរទេស
- ស្នើសុំចុះបញ្ជិកាកិច្ចសន្យាការងារជនបរទេសនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ត្រូវស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស សម្រាប់កម្មករនិយោជិតជាជនបរទេសនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស (https://www.fwcms.mlvt.gov.kh)
- ត្រូវផ្តល់បណ្ណការងារ និងសៀវភៅការងារជនបរទេស និងកិច្ចសន្យាការងារជនបរទេសដែលមានបញ្ជិកាដល់សាមីកម្មករនិយោជិតជាជនបរទេស
- ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក ចូល-ចេញ ព្រមទាំងកត់ត្រាក្នុងសៀវភៅការងាររបស់កម្មករនិយោជិតជាជនបរទេសអំពីតួនាទី ប្រាក់ឈ្នួល ថ្ងៃខែឆ្នាំចូល-ចេញធ្វើការ និងឈ្មោះសហគ្រាស គ្រឹះស្ថាន ដែលបានប្តូរទៅ ក្នុងរយៈពេលមិនលើស ១៥ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលឱ្យធ្វើការ ឬបញ្ឈប់លែងឱ្យធ្វើការ
- ត្រូវអភិវឌ្ឍធនធានមនុស្សមិនឱ្យលើសពី ៥ឆ្នាំ ដោយផ្ទេរមុខជំនាញរបស់កម្មករនិយោជិតឯកទេស ជាជនបរទេស មកដល់កម្មករនិយោជិតខ្មែរ។

ខ. កាតព្វកិច្ចរបស់ជនបរទេសដែលជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា៖

- ត្រូវមានសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន
- ត្រូវបង្ហាញភស្តុតាងស្របច្បាប់ អំពីការអនុញ្ញាតប្រកបអាជីវកម្មរបស់សហគ្រាស គ្រឹះស្ថាន
- ត្រូវស្នើសុំបណ្ណការងារជនបរទេសនៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មបរទេស។

គ. កាតព្វកិច្ចរបស់កម្មករនិយោជិតជាជនបរទេស៖

- ត្រូវដឹងព័ត៌មានអំពីការអនុញ្ញាតប្រកបអាជីវកម្មរបស់សហគ្រាស គ្រឹះស្ថាន
- ត្រូវចុះហត្ថលេខាលើកិច្ចសន្យាការងារជាមួយម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន

- ត្រូវទទួលបានកិច្ចសន្យាការងារជនបរទេសដែលមានបញ្ជិកា
- ត្រូវទទួលបានបណ្ណការងារ និងសៀវភៅការងារជនបរទេសពីម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន
- ត្រូវមានការអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

អធិការការងារ អាចដកហូតបណ្ណការងារជនបរទេសក្នុងលក្ខខណ្ឌណាមួយដូចខាងក្រោមៈ

- ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានជាជនបរទេសមិនមានបណ្ណការងារមុនពេលប្រកបមុខរបរ
- ជនបរទេសត្រូវបានរកឃើញថាចូលមកព្រះរាជាណាចក្រកម្ពុជាមិនត្រឹមត្រូវតាមផ្លូវច្បាប់
- ជនបរទេសត្រូវបានរកឃើញថាប្រើប្រាស់លិខិតឆ្លងដែនមិនត្រឹមត្រូវ
- ជនបរទេសត្រូវបានរកឃើញថាមិនមានទិដ្ឋាការស្នាក់នៅត្រឹមត្រូវ
- ជនបរទេសត្រូវបានរកឃើញថាមានកាយសម្បទាមិនសមស្របនឹងមុខរបរ ឬមានជំងឺឆ្លងណាមួយ
- មុខរបររបស់ជនបរទេសនោះមានការប្រជែងជាមួយកម្មករនិយោជិតខ្មែរ។ ក្នុងករណីនេះ ការដកហូតត្រូវអនុវត្តនៅក្រោយពេលផុតកំណត់នៃបណ្ណការងារ
- ជនបរទេសជាអ្នកកាន់បណ្ណគ្មានការងារធ្វើលើសពីរយៈពេលមួយខែ ឬជននោះបានចូលទៅធ្វើការជាមួយនិយោជកដទៃទៀត
- ជនបរទេសជាអ្នកកាន់បណ្ណបានរាយការណ៍ក្លែងបន្លំអំពីជីវប្រវត្តិ អាជីពការងារ កន្លែងធ្វើការងារ កន្លែងស្នាក់នៅ និងឯកសារសាធារណៈរបស់ខ្លួន។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ